ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.០៧៤...សស.នគ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

# សម្រេច

**ប្រការ១**._

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាល ទាក់ទងនឹងការគ្រប់គ្រងនិងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ២**._

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣**._

ខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃនេះតទៅ។

ថ្ងៃ អង្គារ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១

**ម៉ម ប៊ុនហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំ
## ស្តីពី
# វិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹង ការគ្រប់គ្រង និងការចាត់ចែងសាកសព ដែលមានផ្ទុកមេរោគកូវីដ-១៩

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល លេខ០៧៨ ស.នក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ ស្តីពីវិធានការសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការ ចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩

## ១. សេចក្តីផ្តើម

### សាវតារ និងសនិទានកម្ម

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ត្រូវបានរៀបចំឡើងស្របតាមខ្លឹមសារនៃ នៃអនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្តីពី វិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០២១។

ហានិភ័យនៃការចម្លងមេរោគកូវីដ-១៩ នៅពេលរៀបចំចាត់ចែងសពអ្នកជំងឺកូវីដ-១៩ កើតឡើងដោយៈ

- ការប៉ះពាល់ដោយផ្ទាល់ជាមួយសាកសព ឬវត្ថុរាវដែលហូរចេញពីខ្លួនសាកសព ហើយមានផ្ទុកមេរោគកូវីដ-១៩ ។
- ការប៉ះពាល់ដោយផ្ទាល់ជាមួយរបស់របរនានាដែលមានផ្ទុកមេរោគកូវីដ-១៩ ។

មេរោគនៃជំងឺកូវីដ-១៩(SARS-CoV-2) អាចរស់នៅផ្ទៃវត្ថុជាច្រើនម៉ោង នៅក្នុងបរិស្ថានខាងក្រៅខ្លួនមនុស្ស។ មេរោគនេះក៏ស្ថិតជាមួយសាកសពអ្នកជំងឺកូវីដ-១៩ យូរផងដែរ។ ដូច្នេះ អ្នកដែលមានភារកិច្ចរៀបចំចាត់ចែងសពអ្នកជំងឺកូវីដ-១៩ និងសង្ស័យជំងឺកូវីដ-១៩ ត្រូវការពារខ្លួនដោយប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស ស្រោមដៃ វ៉ែនតាការពារភ្នែក និងរបាំងការពារមុខ អាវបំពង់ដៃវែង មិនជ្រាបទឹក ជាដើម (PPE)។

### គោលបំណង

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រងនិងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ មានគោលបំណងៈ

- រក្សាសុវត្ថិភាពក្នុងការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ឱ្យបានសមស្របតាមបទដ្ឋានវេជ្ជសាស្ត្រ និងនិយាមវប្បធម៌ ប្រពៃណី និងសាសនា នៅក្នុងបរិបទនៃជំងឺកូវីដ-១៩ ។
- បង្ការ និងទប់ស្កាត់ការចម្លងនៃជំងឺកូវីដ-១៩ និងកាត់បន្ថយហានិភ័យសុខភាពសាធារណៈ ដោយអនុវត្តតាមវិធានការសុខាភិបាល និងរក្សាបរិស្ថានអនាម័យល្អនៅមូលដ្ឋានសុខាភិបាល និងទីតាំងបូជាសពឬបញ្ចុះសព ។

## ក្រុមប្រជាជនជាគោលដៅ

គោលការណ៍ណែនាំនេះ គឺជាឧបករណ៍បច្ចេកទេស សម្រាប់គ្រូពេទ្យ បុគ្គលិកសុខាភិបាល បុគ្គលិកផ្នែករក្សា/តំកល់សព អ្នកដឹកជញ្ជូនសព មន្ត្រីធម្មការនិងសាសនា មន្ត្រីបរិស្ថាន និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ក្រុមគ្រួសារសព ព្រះសង្ឃ អាចារ្យវត្ត ក្រុមអ្នកបូជាសព ឬបញ្ចុះសព ។ល។ ប្រើប្រាស់ក្នុងការរៀបចំចាត់ចែងសពអ្នកជំងឺកូវីដ១៩ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

## ការគ្រប់គ្រងនិងចាត់ចែងសពអ្នកជំងឺកូវីដ-១៩

ការគ្រប់គ្រងនិងចាត់ចែងសពអ្នកជំងឺកូវីដ-១៩ ទាក់ទងនឹងសកម្មភាពសំខាន់ៗមួយចំនួន ដូចជា៖

1. ការរៀបចំសាកសពភ្លាមៗ បន្ទាប់ពីស្លាប់ និងមុនពេលបញ្ជូនចេញ
2. ការរក្សាសព ឬតំកល់សព
3. ការដឹកជញ្ជូនសពទៅកាន់ទីបូជាសព ឬបញ្ចុះសព
4. ការបូជាសពឬបញ្ចុះសព
5. ការសម្អាតបរិស្ថាន នៅមូលដ្ឋានសុខាភិបាល យានយន្តដឹកជញ្ជូនសព ទីតាំងបូជាឬបញ្ចុះសព

សកម្មភាពនៃការគ្រប់គ្រងសព ត្រូវអនុវត្តដោយអ្នកពាក់ព័ន្ធផ្ទាល់ ដូចជាគ្រូពេទ្យ បុគ្គលិកសុខាភិបាល អ្នកទុកដាក់សព ក្រុមអ្នកដឹកជញ្ជូនសព ក្រុមអ្នកបូជាសពឬបញ្ចុះសព គ្រួសារសពជាដើម។ ក្រុមមនុស្សទាំងអស់នេះប្រឈមនឹងហានិភ័យនៃការចម្លងកូវីដ-១៩។ ដូច្នេះ ការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ត្រូវអនុវត្តឱ្យបានម៉ត់ចត់នូវវិធានការការពារខ្លួន ដោយប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួន និងសម្ភារៈចាំបាច់ផ្សេងទៀតឱ្យបានត្រឹមត្រូវ ទៅតាមកាលៈទេសៈនិមួយៗ ឧ. ពេលរៀបចំសព និងរក្សាសព នៅក្នុងមន្ទីរពេទ្យ ពេលដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យ ពេលបូជាសព ឬបញ្ចុះសព ជាដើម ។

## ឧបករណ៍ការពារខ្លួន និងសម្ភារៈចាំបាច់ក្នុងការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩

តារាងខាងក្រោមរៀបរាប់អំពីឧបករណ៍ការពារផ្ទាល់ខ្លួន និងសម្ភារៈចាំបាច់នានា សម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ដើម្បីរក្សាសុវត្ថិភាពបុគ្គល និងរក្សាបរិស្ថាន អនាម័យល្អ នៅក្នុងមន្ទីរពេទ្យ យានយន្តដឹកជញ្ជូនសព និងទីតាំងបូជាសព ឬបញ្ចុះសព។ សូមពិនិត្យមើលបន្ថែមអំពីប្រភេទឧបករណ៍ និងសម្ភារៈដែលត្រូវប្រើប្រាស់ ទៅតាមសកម្មភាពជាក់លាក់និមួយៗ នៃការគ្រប់គ្រងសព នៅទំព័រក្រោយៗ។

អ្នកពាក់ព័ន្ធនឹងការគ្រប់គ្រងសពអាចប្រើប្រាស់តារាងនេះជា«**បញ្ជីផ្ទៀងផ្ទាត់**» ដើម្បីបញ្ជាក់ថាឧបករណ៍ការពារខ្លួន និងសម្ភារៈចាំបាច់នានា ដែលត្រូវការចាំបាច់ ត្រូវបានត្រៀមបម្រុងរួចជាស្រេច សម្រាប់ការប្រើប្រាស់ នៅមុន និងក្រោយពេលអនុវត្តសកម្មភាពនិមួយៗ ។

| ឧបករណ៍ការពារខ្លួននិងសម្ភារៈចាំបាច់ក្នុងការគ្រប់គ្រងចាត់ចែងសពអ្នកជំងឺកូវីដ-១៩ | | ផ្ទៀងផ្ទាត់ |
|---|---|---|
| ការលាងសម្អាតដៃ | 1. ទឹកអាល់កុលសម្រាប់លាងសម្អាតដៃ<br>2. ទឹកស្អាត<br>3. សាប៊ូ<br>4. ក្រដាសជូតដៃប្រើហើយបោះចោល | ✓<br>✓<br>✓<br>✓ |
| សម្ភារៈនិង ឧបករណ៍ ការពារខ្លួន | 1. ស្រោមដៃ (ប្រើម្តងបោះចោល ឬ ស្រោមដៃធ្វើការធ្ងន់ៗ)<br>2. ស្រោមដៃជ័រ<br>3. ស្បែកជើងកវែង<br>4. អាវបំពង់ដៃវែង<br>5. អាវអៀមប្លាស្ទិកមិនជ្រាបទឹក<br>6. វ៉ែនតាការពារភ្នែក<br>7. របាំងការពារមុខ<br>8. ម៉ាសពេទ្យ<br>9. ម៉ាស N95 ឬម៉ាសការពារមានតម្រងកម្រិតប្រហែលគ្នា (ប្រើតែក្នុងករណីអាចមានតំណក់ទឹកតូចៗ តាមផ្លូវដង្ហើម ឬវត្ថុរាវចេញពីខ្លួនសពប៉ុណ្ណោះ) | ✓<br>✓<br>✓<br>✓<br>✓<br>✓<br>✓<br>✓<br>✓ |
| ការគ្រប់គ្រង សំណល់និងការ សម្អាតបរិស្ថាន | 1. ថង់ផ្លាស្ទិច សម្រាប់ដាក់សព<br>2. ថង់ដាក់សំណល់ឆ្លងរោគ (ប្រើម្តងហើយបោះចោល)<br>3. សាប៊ូ និងទឹក ឬសាប៊ូបោកសម្លៀកបំពាក់<br>4. សារធាតុរាវសម្រាប់សម្លាប់មេរោគលើផ្ទៃរឹង៖ សូលុយស្យុងអ៊ីប៉ូក្លរីត 0,១% (១000 ppm) ឬ អេតាណុលកម្រិត ៧0% ឬសារធាតុសម្លាប់មេរោគដែលប្រើនៅក្នុងមន្ទីរពេទ្យ។ | ✓<br>✓<br>✓<br>✓ |

# ២. គោលការណ៍គ្រឹះនៃការគ្រប់គ្រងសព

ការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ជាសមត្ថកិច្ចរបស់មន្ទីរពេទ្យនិងអាជ្ញាធរមានសមត្ថកិច្ច។ ការរៀបចំសពបន្ទាប់ពីស្លាប់ភ្លាម និងមុនពេលបញ្ជូនចេញពីមន្ទីរពេទ្យ គឺជាភារៈកិច្ចរបស់មន្ទីរពេទ្យ រីឯការដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យទៅកាន់ទីតាំងបូជាសពឬបញ្ចុះសពដែលត្រូវបានកំណត់ដោយអាជ្ញាធរមូលដ្ឋាន គឺជាភារៈកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ការដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យ និងការបូជាសពឬបញ្ចុះសព ត្រូវធ្វើឡើងឱ្យបានឆាប់តាមដែលអាចធ្វើបាន។

ការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ត្រូវឈរលើគោលការណ៍គ្រឹះ ៣ យ៉ាង ដើម្បីការពារសេចក្តីថ្លៃថ្នូររបស់សព និងរក្សាតុល្យភាពរវាង សិទ្ធិរបស់គ្រួសារសព ភាពចាំបាច់ក្នុងការស្រាវជ្រាវរកមូលហេតុនៃការស្លាប់ និងហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ ។

### គោលការណ៍គ្រឹះ នៃការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩

| ១. សុវត្ថិភាពនៃការរៀបចំទុកដាក់សព | ២. គោរពសេចក្តីថ្លៃថ្នូររបស់សព | ៣. បន្ថយហានិភ័យសុខភាពសាធារណៈ |
|---|---|---|
| អនុវត្តវិធានបង្ការការឆ្លងរោគតាមនិយាមស្តង់ដារ ដោយមានសម្ភារៈលាងសម្អាតដៃឬទឹកសម្លាប់មេរោគ និងពាក់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ។ | រៀបចំទុកដាក់សពឱ្យបានសមរម្យ តាមទំនៀមទម្លាប់ប្រពៃណី និងសាសនា ដោយ ផ្អែកតាមកម្រិតហានិភ័យនៃការចម្លងជំងឺកូវីដ-១៩។ | សម្អាតបរិស្ថាន និងរក្សាអនាម័យល្អ ដើម្បីបង្ការការឆ្លងរោគនៅមន្ទីរពេទ្យ កន្លែងរក្សាសព ទីបូជាសពឬបញ្ចុះសព និងបរិវេណជុំវិញទីកន្លែងទាំងនោះ។ |



# ៣. សកម្មភាពនៃការគ្រប់គ្រងសព

ការគ្រប់គ្រងសព គឺជាលំហូរសកម្មភាពនៃការរៀបចំចាត់ចែងសពអ្នកជំងឺដែលបានស្លាប់ ដោយចាប់ផ្ដើមពីការរៀបចំសពនៅក្នុងបន្ទប់អ្នកជំងឺនៅមន្ទីរពេទ្យ ការចាត់ចែងដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យ រហូតដល់ការរៀបចំពិធីបូជាសពឬបញ្ចុះសព។ រូបភាពខាងក្រោមបង្ហាញពីសកម្មភាពសំខាន់ៗ ក្នុងការគ្រប់គ្រងសព។ សកម្មភាពទាំងអស់ប្រព្រឹត្តឡើងនៅតាមទីតាំងផ្សេងៗគ្នា ហើយទាក់ទងនឹងអ្នកអនុវត្តច្រើនផ្នែក ។

**សកម្មភាពសំខាន់ៗ នៃការគ្រប់គ្រងសព៖ ទីកន្លែង និងអ្នកពាក់ព័ន្ធ**



១. ការរៀបចំសពនៅបន្ទប់អ្នកជំងឺ
គ្រូពេទ្យ បុគ្គលិក



២. ការរៀបចំទុកដាក់សពនៅបន្ទប់រក្សាសព
បុគ្គលិកបន្ទប់រក្សាសព



៣. ការដឹកសពទៅកាន់ទីតាំងបូជាសពឬបញ្ចុះសព
ក្រុមអ្នកដឹកជញ្ជូន



៤. ការរៀបចំសពនៅទីតាំងបូជាសពឬបញ្ចុះសព
ព្រះសង្ឃ អាចារ្យ អ្នកបូជា/បញ្ចុះសព គ្រួសារសព



៥. ការគ្រប់គ្រងនិងសម្អាតបរិស្ថាន
ក្រុមអ្នកសម្អាត



## ១. ការរៀបចំសពនៅមន្ទីរពេទ្យ

ចាប់ផ្តើមដោយការរៀបចំសម្អាត និងរុំសព(វេចខ្ចប់)នៅមុនពេលបញ្ជូនសពចេញពីបន្ទប់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យ។ ក្រោយរៀបចំចប់សព្វគ្រប់ ត្រូវបញ្ជូនសពចេញឱ្យបានលឿនបំផុតតាមដែលអាចធ្វើបានឆ្ពោះទៅកាន់ទីតាំងបូជាសពឬបញ្ចុះសព។

គ្រូពេទ្យ បុគ្គលិក ដែលមានភារកិច្ចរៀបចំសព ត្រូវអនុវត្តតាមវិធានការខាងក្រោម៖

| វិធានការត្រូវអនុវត្ត | | |
|---|---|---|
| 1. | លាងដៃឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូ មុន និងក្រោយពេលប៉ះពាល់សព ព្រមទាំងសម្អាតបរិស្ថាននៅជុំវិញទីនោះឱ្យបានស្អាតល្អ។ | ✓ |
| 2. | ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស់ពេទ្យធម្មតា អាវពេទ្យ និងស្រោមដៃ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីសាកសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវអៀមមិនជ្រាបទឹកបន្ថែមទៀត។ | ✓ |
| 3. | កាត់បន្ថយការធ្វើចលនាសាកសពឱ្យនៅតិចបំផុត ដោយចៀសវាង លើកទុកដាក់សាកសពដែលមិនចាំបាច់ ដើម្បីបង្ការការចេញខ្យល់ ឬទឹកពីក្នុងសួត ឬពីសាកសព។ | ✓ |
| 4. | ដោះសម្ភារៈ បរិក្ខារពេទ្យ ដែលនៅជាប់នឹងខ្លួនសពឱ្យអស់ ដូចជាខ្សែ សេរ៉ូម ម្ជុល ឬបំពង់ផ្សេងៗ នៅមុនពេលរៀបចំរុំសព។ | ✓ |
| 5. | មិនចាំបាច់សម្លាប់មេរោគលើសព ឬចាក់សារធាតុរាវផ្សេងៗ ចូលទៅក្នុងសារពាង្គកាយសពទេ ដូចជាហ្វ័រម៉ុលដើម្បីរក្សាទុកសព។ | ✓ |
| 6. | រុំសពដោយក្រណាត់និងថង់ប្លាស្ទិក | ✓ |
| 7. | សរសេរសម្គាល់លើក្រណាត់រុំសព ដោយដាក់ថា «កូវីដ១៩» | ✓ |
| 8. | រៀបចំចប់សព្វគ្រប់ ត្រូវបញ្ជូនសពចេញពីបន្ទប់សម្រាកព្យាបាលឬប្រពោធនកម្មឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ | ✓ |

## ២. ការរៀបចំទុកដាក់សពនៅបន្ទប់រក្សាសព

អនុញ្ញាតឱ្យរក្សាសពទុកក្នុងបន្ទប់រក្សាសពនៅក្នុងមន្ទីរពេទ្យឬនៅកន្លែងណាមួយដែលត្រូវបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច តែក្នុងករណីដែលសពនោះជាប់ពាក់ព័ន្ធនឹងផ្លូវច្បាប់ ដូចជាចាំបាច់ត្រូវការពិនិត្យស្រាវជ្រាវបន្ថែមដោយអាជ្ញាធរមានសមត្ថកិច្ច។ ទោះជាដូច្នេះក្តី កិច្ចការស្រាវជ្រាវនោះ ត្រូវធ្វើឱ្យបានលឿនបំផុតតាមដែលអាចធ្វើបាន បន្ទាប់មកត្រូវបញ្ជូនសពទៅកាន់ទីតាំងបូជាសពឬបញ្ចុះសពឱ្យបានឆាប់បំផុតផងដែរ។

**ក្នុងបន្ទប់រក្សាសព**

មន្ទីរពេទ្យទាំងអស់ត្រូវរក្សាអនាម័យ និងបរិស្ថានល្អ ជាប្រចាំ នៅក្នុងបន្ទប់រក្សាសព ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ស្តីពីការបង្ការ និងការគ្រប់គ្រងការឆ្លងរោគ នៅមូលដ្ឋានសុខាភិបាល ។

**បុគ្គលិកផ្នែករក្សាសព**

បុគ្គលិកផ្នែករក្សាសព ដែលមានភារៈកិច្ចរៀបចំទុកដាក់សពនៅក្នុងបន្ទប់រក្សាសព ត្រូវប្រើឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដោយត្រូវពាក់ម៉ាស់ ស្រោមដៃ វ៉ែនតាការពារភ្នែក អាវពេទ្យ និងពាក់អាវអៀមមិនជ្រាបទឹកពីលើមួយជាន់ទៀត។ សម្ភារៈទាំងនោះត្រូវប្រើតែម្តងគត់ ហើយត្រូវបោះចោលឱ្យបានត្រឹមត្រូវ តាមការណែនាំ។

| វិធានការត្រូវអនុវត្ត និងឧបករណ៍/សម្ភារៈការពារខ្លួន | |
|---|---|
| 1. អនាម័យដៃ (លាងសម្អាតដៃ) | ✓ |
| 2. ស្រោមដៃប្រើម្តងបោះចោល | ✓ |
| 3. ម៉ាសពេទ្យ | ✓ |
| 4. ស្រោមដៃជ័រ | ✓ |
| 5. អាវពេទ្យ | ✓ |
| 6. អាវអៀមមិនជ្រាបទឹកពីលើមួយជាន់ (បើគិតថាអាចមានហូរទឹកចេញពីសាកសព) | ✓ |
| 7. របាំងការពារមុខ(ជម្រើសទី១) ឬវ៉ែនតាការពារភ្នែក | ✓ |

## ៣. ការដឹកសពចេញពីមន្ទីរពេទ្យ

សពដែលត្រូវបានរុំ/វេចខ្ចប់ត្រឹមត្រូវរួចរាល់ហើយ ត្រូវបញ្ជូនចេញពីមន្ទីរពេទ្យ ឱ្យបានឆាប់តាមដែលអាចធ្វើបាន ឆ្ពោះទៅកាន់ទីតាំងបូជាសព ឬបញ្ចុះសពដែលបានកំណត់។

**ទីដៅនៃការដឹកជញ្ជូនសព**

ការដឹកជញ្ជូនសពអ្នកជំងឺកូវីដ-១៩ ចេញពីមន្ទីរពេទ្យ ត្រូវឆ្ពោះទៅកាន់ទីតាំងបូជាសព ឬបញ្ចុះសពតែម្តង។

**មធ្យោបាយដឹកជញ្ជូន៖**

សពត្រូវបានដឹកតាមរថយន្តដឹកសព ឬតាមមធ្យោបាយដឹកជញ្ជូនសមស្របផ្សេងៗទៀត យោងទៅតាមស្ថានការណ៍ជាក់ស្តែង។ យោងតាមអង្គការសុខភាពពិភពលោក ការដឹកជញ្ជូនសពអ្នកជំងឺកូវីដ១៩ មិនចាំបាច់ប្រើប្រាស់រថយន្ត ឬឧបករណ៍អ្វីពិសេសនោះទេ។

**ក្រុមអ្នកដឹកជញ្ជូនសព**

ក្រុមអ្នកដឹកជញ្ជូនសពអាចប្រឈមនឹងហានិភ័យនៃការឆ្លងកូវីដ១៩ ពីសាកសព។ ដូច្នេះក្រុមអ្នកដឹកជញ្ជូនសពត្រូវប្រុងប្រយ័ត្នជានិច្ចនៅពេលលើកទុកដាក់សព ដោយត្រូវអនុវត្តតាមវិធានការណែនាំខាងក្រោម។

| វិធានការត្រូវអនុវត្ត | | |
|---|---|---|
| 1. | លាងដៃឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូឬទឹកសម្លាប់មេរោគ នៅមុននិងក្រោយពេលលើកទុកដាក់សព។ | ✓ |
| 2. | ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស់ពេទ្យធម្មតា (surgical mask) ស្រោមដៃ អាវពេទ្យ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីខ្លួនសាកសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវអៀមមិនជ្រាបទឹក បន្ថែមទៀត ។ | ✓ |
| 3. | បន្ថយការលើកទុកដាក់សាកសព ចុះឡើងឱ្យនៅតិចបំផុត | ✓ |
| 4. | លាងសំអាតរថយន្ត ឬមធ្យោបាយដឹកជញ្ជូន ទាំងផ្នែកខាងក្នុង និងខាងក្រៅ ដោយប្រើទឹកសម្លាប់មេរោគ នៅក្រោយពេលដឹកជញ្ជូនរួចម្តងៗ ។ | ✓ |

## ៤. ការរៀបចំសពនៅទីបូជាសពឬបញ្ចុះសព

ការរៀបចំពិធីបុណ្យសពគប្បីប្រព្រឹត្តទៅតាមទំនៀមទម្លាប់ ប្រពៃណី និងសាសនា ក្រោមការរៀបចំចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច។ ដោយមានការកំណត់ចំនួនមនុស្សចូលរួមក្នុងកម្រិតអប្បបរមា ដើម្បីរក្សាគម្លាតសុវត្ថិភាពសង្គម និងបុគ្គល។ នៅក្នុងពិធីបុណ្យសព គ្រួសារ/ញាតិមិត្តរបស់សព ព្រះសង្ឃ អាចារ្យ ក្រុមអ្នកបូជាសព ឬបញ្ចុះសព គប្បីអនុវត្តតាមវិធានការណែនាំខាងក្រោម។

### ក្រុមអ្នកបូជា

អ្នកបូជាសពឬបញ្ចុះសព អាចប្រឈមនឹងហានិភ័យនៃការចម្លងកូវីដ-១៩ ។ ដូច្នេះដើម្បីសុវត្ថិភាព អ្នកមានភារកិច្ចលើកសាកសពដាក់ចូលក្នុងមឈ្ឈូស និងលើកមឈ្ឈូសដាក់លើទីតាំងបូជា ត្រូវពាក់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស និងស្រោមដៃ។ នៅពេលរៀបចំរួចរាល់ ត្រូវដោះឧបករណ៍ការពារខ្លួនដែលប្រើរួចចោលឱ្យបានត្រឹមត្រូវ ហើយលាងសម្អាតដៃជាមួយសាប៊ូនឹងទឹកស្អាតភ្លាមៗ។

| វិធានការត្រូវអនុវត្ត | | |
|---|---|---|
| 1. | លាងដៃឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូ ឬទឹកសម្លាប់មេរោគ មុននិងក្រោយពេលលើកទុកដាក់សព។ | ✓ |
| 2. | ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស់ពេទ្យធម្មតា (surgical mask) ស្រោមដៃ អាវពេទ្យ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីខ្លួនសាកសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវអៀមមិនជ្រាបទឹកបន្ថែមទៀត ។ | ✓ |
| 3. | បន្ថយការលើកទុកដាក់សាកសព ចុះឡើងឱ្យនៅតិចបំផុត | ✓ |
| 4. | លាងសំអាតរថយន្ត ឬមធ្យោបាយដឹកជញ្ជូនទាំងផ្នែកខាងក្នុង និងខាងក្រៅ ដោយប្រើទឹកសម្លាប់មេរោគនៅក្រោយពេលដឹកជញ្ជូនរួចម្តងៗ ។ | ✓ |

### គ្រួសារ/ញាតិមិត្តរបស់សព

- គ្រួសារនិងញាតិមិត្តរបស់សព អាចទៅកាន់ទីតាំងបូជាឬបញ្ចុះ តាមចំនួនដែលត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច។
- នៅពេលដែលសពបូជារួចហើយ អាជ្ញាធរមូលដ្ឋានត្រូវប្រគល់អដ្ឋិធាតុជូនគ្រួសារសពរក្សាទុកតាមទំនៀមទម្លាប់ប្រពៃណី។
- ក្នុងករណីដែលសាកសពពុំមានគ្រួសារ អាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច ទទួលខុសត្រូវរក្សាទុកអដ្ឋិធាតុ ដោយមានការសម្គាល់អត្តសញ្ញាណអដ្ឋិធាតុ ដើម្បីទុកជូនគ្រួសារសព។

## ៥. ការគ្រប់គ្រងនិងសម្អាតបរិស្ថាន

ក្នុងលក្ខខណ្ឌនៃការពិសោធន៍បានបញ្ជាក់ថា វីរុសកូវីដ-១៩ អាចរស់នៅបានជាច្រើនម៉ោង នៅក្នុងបរិស្ថានខាងក្រៅខ្លួនមនុស្ស។ ដូច្នេះការលាងសម្អាត និងរក្សាបរិស្ថានអនាម័យល្អបានត្រឹមត្រូវ គឺមានសារៈសំខាន់ណាស់។ វិធានដែលត្រូវអនុវត្ត ដើម្បីរក្សាបរិស្ថានអនាម័យល្អ មានដូចតទៅ៖

1. បុគ្គលិកសម្អាតអនាម័យត្រូវប្រើប្រាស់ឧបករណ៍ការពារខ្លួន ដូចជា៖ ឧបករណ៍ការពារផ្លូវដង្ហើម និងភ្នែក ក្នុងពេលរៀបចំ និងប្រើប្រាស់សារធាតុសម្លាប់មេរោគ។
2. បន្ទប់រក្សាសពត្រូវរក្សាអនាម័យជានិច្ច មានខ្យល់ចេញចូលគ្រប់គ្រាន់ជាប្រចាំ និងមានពន្លឺគ្រប់គ្រាន់ផងដែរ ។
3. ត្រូវលាងសម្អាតឧបករណ៍ដែលបានប្រើប្រាស់ ក្នុងពេលពិនិត្យសាកសពនិមួយៗ និងសម្លាប់មេរោគភ្លាមៗបន្ទាប់ពីពិនិត្យរួច។
4. ត្រូវលាងសម្អាតផ្ទៃ និងបរិស្ថានក្នុងបន្ទប់ដែលដាក់សាកសព ជាមួយសាប៊ូ(ម្សៅសាប៊ូនឹងទឹក) បន្ទាប់ពីលាងសម្អាតជាមួយទឹករួច ត្រូវលាងសម្អាតផ្ទៃនោះជាមួយសារធាតុអេតាណុល ៧០% យ៉ាងហោចឱ្យបាន ១ នាទី ឬសារធាតុសម្លាប់មេរោគដែលមានកំហាប់សូដ្យូមអ៊ីប៉ូក្លរីតយ៉ាងតិច ០,១% (១០០០ ppm)។
5. ត្រូវគ្រប់គ្រង ទុកដាក់ និងចោលសំណល់ផ្សេង ឱ្យបានត្រឹមត្រូវស្របតាមនិតិវិធី និងគោលការណ៍ណែនាំស្ដីពីការបង្ការ និងគ្រប់គ្រងការឆ្លងរោគ របស់ក្រសួងសុខាភិបាល។